**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**ក្រុមលទ្ធកម្ម**
លេខ : ០១ កល.ស.ភ.ភ.ព.លទ

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់សម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
## សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន
## ដោយប្រើប្រាស់ថវិកាកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន
## របស់អង្គភាពថវិកាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដោយប្រើប្រាស់ថវិកាកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន របស់អង្គភាពថវិកាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់និងស្របតាមបទប្បញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមានអាសយដ្ឋាន អគារSTEM ជាន់ទីប្រាំមួយ បន្ទប់លេខ៦០៤ មហាវិថីសហពន្ធ័រុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ៨៨០ ៦៤៩ អ៊ីមែល: rupp.procurement@gmail.com គេហទំព័រ www.rupp.edu.kh ចាប់ពីថ្ងៃ ២៥ ខែមករា ឆ្នាំ២០២២ តទៅ រៀងរាល់ម៉ោងធ្វើការ ។ អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយឯកសារដេញថ្លៃនូវលិខិតធានាប្រាក់កក់ការដេញថ្លៃ ដែលមានទឹកប្រាក់ចំនួន **៦៦០.០០ ដុល្លារ (ប្រាំមួយរយហុកសិបដុល្លារអាមេរិកគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូ ណាមួយដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មានទម្រង់ និងខ្លឹមសារដូចក្នុង គំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ៣:០០ រសៀល ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម អាសយដ្ឋាន អគារSTEM ជាន់ទី០៧ បន្ទប់លេខ៧០៥ មហាវិថីសហពន្ធ័រុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅវេលាម៉ោង ៣:០០ រសៀលថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ចន្ទ ៧ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០២២
**សាកលវិទ្យាធិការរង និងជាប្រធានក្រុមលទ្ធកម្ម**

**ពន់ ឆាយ**

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ